# ទ្រខ្មែរ៖ រូបតំណាងលើប្រាសាទបាយ័ន

អត្ថបទនេះ នឹងពិនិត្យទៅលើឧបករណ៍តន្ត្រី ទ្រខ្មែរឬទ្រខ្សែបី ព្រមទាំងប្រភេទទ្រស្រដៀងនឹងទ្រខ្មែរនៅលើពិភពលោកផងដែរ ដែលរួមមាន៖ សសាមសៃថៃ វីណាប់អេហ្ស៊ីប វីណាប់ឥណ្ឌូណេស៊ីនិងម៉ាឡេស៊ី វីណាប់អារ៉ាប់ ទួរគី និងអាហ្វហ្កានីស្ថាន វីបិកអឺរ៉ុប កាម៉ាន់ចេអ៊ីរ៉ង់ (កាម៉ាន់ចា តាល និងហ្គេចាស) និងកាម៉ាន់ចាអាហ្ស៊ែបៃហ្សានៗ

ពាក់ព័ន្ធនឹងឧបករណ៍តន្ត្រីខាងលើនេះ បញ្ញវ័នអ្នកស្រាវជ្រាវជាច្រើនបានសរសេរយ៉ាងក្បោះក្បាយៗ នៅក្នុងនោះ អ្នកស្រីសារ៉ា បូហ្គេន បានអះអាងថា ឧបករណ៍តន្ត្រីគ្រឿងខ្សែកូត បានហូរចូលពីប្រទេសពែរក្សទៅប្រទេសចិន ដែលមានប្រជាប្រិយភាពនៅក្នុងអំឡុងឆ្នាំ១២៧៩-១៦៤៤ៗ[១] អ្នកស្រី ក៏បានអះអាងថា ទ្រខ្សែបីថៃ ជាឧបករណ៍តន្ត្រីមួយក្នុងចំណោមឧបករណ៍ឯទៀតដែលគេបានបង្កើតឡើង នៅសម័យអាយុធ្យានាសតវត្សទី១៤ៗ[២] អ្នកស្រីក៏បានបន្តទៀតថា គេបានគិតថាឧបករណ៍ទ្រខ្សែបីថៃ មកពីប្រទេសកម្ពុជានៅពេលដែលថៃលុកលុយប្រទេសកម្ពុជាៗ[៣]

ដោយសារការស្រាវជ្រាវមិនគ្រប់គ្រាន់និងមិនស៊ីជម្រៅ អ្នកស្រីបាននិយាយថា ពាក់ព័ន្ធនឹងប្រភពនឹងដើមកំណើតនៃទ្រខ្មែរ គឺវាបានគេឧទ្ទេសនាមនៅពេលជាមួយគ្នានឹងឧបករណ៍វីណាប់នៅម៉ាឡេស៊ីនិងស៊ូម៉ាត្រានៅចុងសតវត្សទី១៩ៗ[៤] ប៉ុន្តែជាការពិតដោយយោងទៅលើចម្លាក់ដែលជារូបតំណាង ខ្មែរយើងបានឆ្លាក់រូបឧបករណ៍ទ្រខ្មែរនៅលើប្រាសាទបាយ័នតាំងតែពីចុងសតវត្សទី១២និងដើមសតវត្សទី១៣មកម្ល៉េះ ពោលគឺតាំងមុនសតវត្សទី១៥ (សូមមើលរូបភាព)ៗ ម្យ៉ាងទៀត លោកស្រីបានគិតថា ដោយទ្រខ្មែរជាឧបករណ៍តន្ត្រីតែមួយគត់នៅកម្ពុជាដែលមានខ្សែបី វាប្រាកដជាមានប្រភពដើមពីបរទេសហើយៗ[៥]

[១] Bogen 2019: 11
[២] Bogen 2019: 34
[៣] Bogen 2019: 35
[៤] Bogen 2019: 37
[៥] Bogen 2019: 38

អត្ថបទដោយ៖

ពាក់ព័ន្ធនឹងវីរបាប់ គេបានរកឃើញរូបចម្លាក់តូចមួយនៅលើដុំដីដុតនៅប្រទេសអេហ្ស៊ីបដែលមានរូបអ្នកលេងវីរបាប់ក្នុងកាលបរិច្ឆេទអំឡុងឆ្នាំ១០០០ មុនគ្រឹស្តសករាជ្យ។[៦] ឧបករណ៍វីរបាប់បុរាណទាំងនេះ មានខ្សែ១ ២ ឬ៤។ ពីកោះជ្វា ប្រទេសឥណ្ឌូណេស៊ី ឧបករណ៍វីរបាប់ បានធ្វើដំណើរទៅទឹកដីផ្សេងឯទៀតៗលើពិភពលោក។ ដោយឡែកប្រទេសនីមួយៗមានប្រភេទឧបករណ៍វីរបាប់ដោយឡែករៀងៗខ្លួន។ ជាក់ស្តែង វីរបាប់ ជាឧបករណ៍តន្ត្រីមួយដែលមានប្រជាប្រិយភាពជាងគេនៅក្នុងវប្បធម៌អារ៉ាប់ និងប្រទេសអាហ្វហ្កានីស្ថាននិងពែរក្ស។

មានទ្រឹស្តីគួរឱ្យចាប់អារម្មណ៍មួយដែលថាតើឧបករណ៍ និងក្រុមសន្តានវីរបាប់បានធ្វើដំណើរដូចម្តេចទៅទ្វីបអឺរ៉ុប។ អ្នកប្រវត្តិវិទូតន្ត្រី បានអះអាងថាអ្នកផ្សព្វផ្សាយសាសនាគ្រឹស្តបានឧទ្ទេសនាមឧបករណ៍តន្ត្រីអាស៊ីបូព៌ាខ្លះទៅអឺរ៉ុប។ នៅក្នុងអំឡុងពេលប្រមាណពីចុងសតវត្សទី១១ដល់ចុងសតវត្សទី១២ ឧបករណ៍តន្ត្រីអារ៉ាប់ រួមទាំងវីរបាប់ត្រូវបានគេស្គាល់នៅអឺរ៉ុប។[៧] គេឃើញថា វីរបាប់ មានឥទ្ធិពលដ៏ខ្លាំងក្លាទៅលើវប្បធម៌អឺរ៉ុប ដូចដែលបានបង្ហាញដោយឧបករណ៍តន្ត្រី វីរបិក។[៨] លើសពីនេះទៅទៀត ឧបករណ៍ វីរបាប់ ដែលមានប្រជាប្រិយភាពនៅអឺរ៉ុប ហៅថា វីរបិក នោះក៏មានឥទ្ធិពលទៅលើអភិវឌ្ឍន៍នៃឧបករណ៍តន្ត្រីវីយ៉ូឡុងផងដែរ។[៩]

កាម៉ាន់ចេ ជាឧបករណ៍តន្ត្រីប្រកបដោយមោទនភាពរបស់ប្រទេសអ៊ីរ៉ង់។ វាជាឧបករណ៍តន្ត្រីគ្រឿងខ្សែកូតប្រពៃណីតែមួយគត់នៅក្នុងសិល្បៈតន្ត្រីអ៊ីរ៉ង់។ ឧបករណ៍តន្ត្រីខ្សែបីនេះអាចរឹតនិងផ្លាស់ប្តូរក្នុងគម្លាតសូរបួនសុក្រឹតឬប្រាំសុក្រឹត (perfect fourths or perfect fifths)។ ឧបករណ៍នេះត្រូវបានគេកត់ត្រាជាឯកសារលើកទី១នៅប្រទេសពែរក្សនាសតវត្សទី១៩។[១០] ពាក្យ «កាម៉ាន់ចេ» មានពីរម៉ាត់គឺ៖ «កាម៉ាន់» មានន័យថា «កោង» និង «ចេ» ជាពាក្យបន្ថែមខាងចុងនៃពាក្យ មានន័យថា «តូចបំផុត»។[១១] ដូច្នេះ «កាម៉ាន់ចេ» មានន័យ

[៦] Bogen 2019: 41

[៧] Engel n.d.: 79, Bogen 2019: 43

[៨] Bogen 2019: 43
[៩] Bogen 2019: 44
[១០] Bogen 2019: 55
[១១] Oloumi n.d.: 93

ថា «ពង់កោងតូច» សំដៅទៅលើផាករបស់ឧបករណ៍។ សំណេរយោងទី១ទៅលើឧបករណ៍កាម៉ាន់ចេ មានកាលបរិច្ឆេទប្រមាណ១២០០ឆ្នាំមុននេះ។ នៅក្នុង រាជវង្សសាហ្វាវីដ (១៥០១-១៧៣៦) គេបានចាត់ទុកឧបករណ៍តន្ត្រីកាម៉ាន់ចេនេះថាជាឧបករណ៍សំខាន់បំផុត ជាពិសេសនៅក្នុងចំណោមតន្ត្រីករប្រពៃណីដែលលេងភ្លេងនៅតាមផ្លូវនិងទីសាធារណៈ។ នៅក្នុងបរិបទអនុវត្តន៍ គេឃើញមានឧបករណ៍តន្ត្រីកាម៉ាន់ចេបីប្រភេទនៅប្រទេសអ៊ីរ៉ង់គឺ៖ កាម៉ាន់ចា តាល (ល័រីកាម៉ាន់ចេ) និងហ្គេចាស (ទូកមែនសារ៉ា កាម៉ាន់ចេ) មានខ្សែ៣ ៤ ឬ៥ ដែលគេឃើញមានផងដែរនៅប្រទេសអាហ្សឺបៃហ្សាន ហៅថា កាម៉ាន់ចា។

ទ្រខ្មែរ ឬ ទ្រខ្សែ៣ ជាប្រភេទគ្រឿងខ្សែកូតនិងជាឧបករណ៍តន្ត្រីដ៏ចាស់មួយនៅក្នុង ចំណោមឧបករណ៍តន្ត្រីខ្មែរទាំងអស់ ដែលមានចម្លាក់ជារូបតំណាងនៅលើប្រាសាទបាយ័នជាតឹកតាង។ ទ្រខ្មែរ មានប្រអប់សូរប្រវែងប្រមាណ ១៥ ស.ម. (ពីឆ្វេងទៅស្តាំ) និង ២០ ស.ម. (ពីលើមកក្រោម) ធ្វើពីលលាដ៍ដូងស្ងួត កាត់ជាបីយកផ្នែកខាងគូទ ហើយពាសដោយស្បែក ពង្រូលឬពស់ប្រមោយ។ នៅលើសន្ទះស្បែក ផ្នែកខាងលើនិងឆ្វេង គេដាំ «ដោះ» ដែលហៅថា «ដោះទ្រខ្មែរ» ធ្វើពីក្រមួនឃ្មុំលុញទំហំប៉ុនម្រាមដៃ ឬសំបកខ្យងក្តក់ដើម្បីឲ្យមានសូរធ្ងន់ និងរំញ័រល្អ។ ដងទ្រខ្មែរដែលស៊កចូលទៅក្នុងប្រអប់សូរត្រឡោកដូងពីលើមកក្រោមមានប្រវែងប្រមាណ ៨០ ស.ម.។ ទ្រខ្មែរ មានខ្សែបីធ្វើពីសូត្រ នីឡុង ស្ពាន់ ឬដែក និងផាកមានរាងដូចដងធ្នូធ្វើពីឈើខ្ទឹមឬឫស្សី មានខ្សែធ្វើពីសក់កន្ទុយសេះឬដ៏រនីឡុងចងភ្ជាប់ពីចុងទៅគល់ដងផាក ដោយទុកសាច់ឈើបន្តិចសម្រាប់កាន់កូត។ ផាករបស់ទ្រខ្មែរ នៅដាច់ពីឧបករណ៍ មិនដូចជាទ្រឈេ ទ្រសោ ឬទ្រអ៊ូឡើយ។ ទ្រខ្មែរ មានឆ្លាក់ក្បាច់រចនា បង្កប់ដោយភ្លុកឬឆ្អឹងយ៉ាងល្អប្រណិត។

គេរឹតទ្រខ្មែរទៅតាមសូរ A-D-G (A = ខ្សែក្រោម, D = ខ្សែកណ្តាល, G = ខ្សែលើ)។ ពេលសម្តែង គេយកផាកមកដាក់ភ្ជាប់នឹងខ្សែទ្រ ដើម្បីកូតឲ្យឮសូរ។ ពេលត្រូវផ្លាស់ប្តូរពីខ្សែមួយទៅខ្សែមួយទៀត អ្នកលេងបង្វិលតួទ្រទៅឆ្វេងឬស្តាំទៅតាមតម្រូវការ។ តន្ត្រីករខ្មែរខ្លះ មានចំណាប់អារម្មណ៍ថា ការរៀនទ្រខ្មែរ គឺមានការលំបាកជាងការរៀនឧបករណ៍ទ្រឯទៀតៗ។

អត្ថបទដោយ៖

# អត្ថបទ៖ ទ្រខ្មែរ៖ រូបតំណាងលើប្រាសាទបាយ័ន

ឧបករណ៍ទ្រខ្មែរ ដែលប្រើនៅក្នុងវង់តន្ត្រីអារក្សនិងអាពាហ៍ពិពាហ៍បុរាណខ្មែររាប់សតវត្សមកហើយ ជាឧបករណ៍សំខាន់និងនាំមុខគេនៅក្នុងវង់តន្ត្រី ពោលគឺអ្នកលេងទ្រខ្មែរនៅក្នុងវង់តន្ត្រីអារក្ស (អារក្ខ) ដែលមានឧបករណ៍ ទ្រខ្មែរ ខ្សែ១ ចាប៉ីដងវែង ប៉ីពក ប៉ីប្រប៉ុស ឈឹង ស្គរដៃពីពីរឡើងទៅ និងអ្នកច្រៀង ក្នុងជំនឿអរូបី ខ្មោចឬព្រលឹង ជាពិសេសក្នុងពិធីបញ្ចូលរូបឬលៀងអារក្សដើម្បីឲ្យអារក្សសប្បាយរីករាយ ឬពិធីប្រារព្ធសុំភ្លៀងនៅពេលរាំងស្ងួត ពេលស្រុកកើតជំងឺរាតត្បាត ទុរ្ភិក្ស ឬមហន្តរាយក្នុងគោលបំណងសូមសេចក្តីសុខសិរីសួស្តីជ័យមង្គលឲ្យផុតគ្រោះថ្នាក់ចង្រៃផ្សេងៗ ក៏ដូចជានៅក្នុងវង់តន្ត្រីអាពាហ៍ពិពាហ៍បុរាណ ដែលមានឧបករណ៍ ទ្រខ្មែរ ខ្សែ១ ចាប៉ីដងវែង ប៉ីប្រប៉ុស ឈឹង ស្គរដៃ និងអ្នកច្រៀង គឺអ្នកលេងទ្រខ្មែរដែលមានតួនាទីផ្តើមបទ ហើយតន្ត្រីករឯទៀតត្រូវទទួលនិងលេងបន្ត រហូតដល់ចប់បទ។

ទ្រខ្មែរ ជាឧបករណ៍តន្ត្រីរបស់ខ្មែរសុទ្ធសាធប្រកបដោយលក្ខណៈ ចរិត អត្តសញ្ញាណ ពណ៌សម្បុរ និងជាព្រលឹងរបស់ខ្មែរ ហើយខ្មែរយើងប្រើនៅក្នុងវង់តន្ត្រីទាំងពីរខាងលើ ដែលមានអាយុកាលចាស់ជាងគេនៅក្នុងចំណោមវង់តន្ត្រីខ្មែរទាំងអស់។

កាលបរិច្ឆេទ សកម្មភាព និងព្រឹត្តិការណ៍ពាក់ព័ន្ធនឹងប្រភេទទ្រខ្សែបីពិភពលោក៖

- គេបានរកឃើញរូបចម្លាក់តូចមួយនៅលើដុំដីដុតនៅប្រទេសអេហ្ស៊ីបដែលមានរូបអ្នកលេងវីយ៉ូឡុងក្នុងកាលបរិច្ឆេទអំឡុងឆ្នាំ១០០០ មុនគ្រឹស្តសករាជ្យ។
- សំណេរយោងទី១ទៅលើឧបករណ៍កាម៉ាន់ចេ មានកាលបរិច្ឆេទប្រមាណ១២០០ ឆ្នាំមុនឆ្នាំ២០១៩ (ដែលឯកសារយោងសរសេរ) គឺសតវត្សទី៩។
- នៅក្នុងអំឡុងពេលប្រមាណពីចុងសតវត្សទី១១ដល់ចុងសតវត្សទី១២ ឧបករណ៍តន្ត្រីអារ៉ាប់ រួមទាំងរេបាប់ត្រូវបានគេស្គាល់នៅអឺរ៉ុប។
- យោងទៅលើចម្លាក់ដែលជារូបតំណាង ខ្មែរយើងបានឆ្លាក់រូបឧបករណ៍ទ្រខ្មែរនៅលើជញ្ជាំងប្រាសាទបាយ័ន (ចុងសតវត្សទី១២-ដើមសតវត្សទី១៣)។
- ឧបករណ៍តន្ត្រីគ្រឿងខ្សែកូត បានហូរចូលពីប្រទេសពែរក្សទៅប្រទេសចិន ដែលមានប្រជាប្រិយភាពនៅក្នុងអំឡុងឆ្នាំ១២៧៩-១៦៤៤។

អត្ថបទដោយ៖

- ទ្រខ្សែបីថៃ ជាឧបករណ៍តន្ត្រីមួយក្នុងចំណោមឧបករណ៍ឯទៀតដែលគេបានបង្កើតឡើងនៅសម័យអាយុធ្យានាសតវត្សទី១៤។
- នៅក្នុងរាជវង្សសាហ្វាវីដ (១៥០១-១៧៣៦) គេបានចាត់ទុកឧបករណ៍តន្ត្រីកាម៉ាន់ចេនេះថាជាឧបករណ៍សំខាន់បំផុត ជាពិសេសនៅក្នុងចំណោមតន្ត្រីករប្រពៃណីដែលលេងក្មេងនៅតាមផ្លូវនិងទីសាធារណៈ។
- ឧបករណ៍កាម៉ាន់ចេ ត្រូវបានគេកត់ត្រាជាឯកសារលើកទី១នៅប្រទេសពែរក្សនាសតវត្សទី១៩។

សរុបសេចក្តីមក យោងទៅលើឯកសារនិងកត្តាខាងលើ យើងអាចលើកជាសំណួរមួយចំនួនដើម្បីពិចារណា៖ ១) រូបតន្ត្រីករលេងឧបករណ៍វៃបាប់ ដែលមានឆ្លាក់នៅលើដុំដីដុត មានកាលបរិច្ឆេទអំឡុងឆ្នាំ១០០០ មុនគ្រឹស្តសករាជ្យ គេរកឃើញនៅប្រទេសអេហ្ស៊ីប អាចយកជាការបានដែរឬទេ? ២) ហេតុអ្វីបានជាគ្មានសកម្មភាពនិងព័ត៌មានពាក់ព័ន្ធនឹងប្រភេទឧបករណ៍វៃបាប់ (ប្រភេទទ្រខ្សែបី) ពិភពលោក នៅក្នុងចន្លោះពេលយ៉ាងយូរពីអំឡុងឆ្នាំ១០០០ មុនគ្រឹស្តសករាជ្យដល់អំឡុងសតវត្សទី៩ នៃគ្រឹស្តសករាជ្យ (ជិតទៅ ២,០០០ឆ្នាំ)? ៣) ឯកសារមួយចំនួនបង្ហាញពីវត្តមានប្រភេទទ្រខ្សែបីនៅក្នុងអំឡុងឆ្នាំ ១០០០ នៃគ្រឹស្តសករាជ្យ ប្រហាក់ប្រហែលនឹងឧបករណ៍ទ្រខ្មែររបស់កម្ពុជា ដែលមានចម្លាក់រូបតំណាងនៅលើប្រាសាទបាយ័នជាតឹកតាង។ ឯកសារដែលមាន មិនបានបង្ហាញថាមានការធ្វើដំណើររបស់ប្រភេទទ្រខ្សែបីពីក្រៅប្រទេសមកកម្ពុជាឡើយ។ ទាំងអស់សុទ្ធតែជាការសន្មត។ ហេតុអ្វី? ៤) តើឯកសារខ្លះឬទាំងអស់ដែលអះអាងអំពីប្រភេទទ្រនៅក្រោមអត្ថបទសិក្សានេះអាចយកជាការបានដែរឬទេ? ខ្ញុំយល់ថាការស្រាវជ្រាវលើប្រធានបទនេះ ត្រូវបន្តទៅទៀតដើម្បីស្វែងរកភាពច្បាស់លាស់និងការពិតពាក់ព័ន្ធនឹងឧបករណ៍តន្ត្រីទ្រខ្សែបី៕

## ឯកសារពិគ្រោះ


កែវ ណារុំ. (២០១១). *តន្ត្រីនៅប្រទេសខ្មែរ*. ភ្នំពេញ: គ្រឹះស្ថានបោះពុម្ពផ្សាយនគរវត្ត។

ពេជ្រ ទុំក្រវិល. (២០០៣). *ទស្សនីយភាពខ្មែរ*. ភ្នំពេញ: រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។


អត្ថបទដោយ៖

Bogen, Sarah A. (2019). *A History of Non-Western Bowed Instruments: A Look into the Eastern History of the Modern-Day Violin*. Thesis, Long Island University. [Quoted Sam-Ang Sam 1995, p. 37]

Engel, Carl. (n.d.). *Researchers into the Early History of the Violin Family*. London: Novello, Ewer and Company.

*Musique Khmère*. (1969). Phnom Penh: Imprimerie Sangkum Réastr Niyum.

Oloumi, Mehdi. (n.d.). "Kamanche, the Bowed String Instrument of the Orient." *International Journal of Arts and Commerce* in www.ijac.org.uk

Sam, Sam-Ang. (2002). *Musical Instruments of Cambodia*. Osaka: National Museum of Ethnology.

Touma, Habib Hassan. (1980). "History of Arabian Music: A Study," *The World of Music*, *22*(3), 66-75.





អត្ថបទដោយ៖









អត្ថបទដោយ៖



អត្ថបទដោយ៖